# អង្គការបណ្ដើមគំនិតការពារ អំពើហឹង្សានៃយុវជនក្រុង Seattle

## ព្រឹត្តិការណ៍ជុំវិញ

អង្គារបណ្ដើមគំនិតការពារអំពើហឹង្សានៃយុវជន ក្រុង Seattle (The **Seattle Youth Violence Prevention Initiative**) គឺជា បណ្ដើមគំនិតដោះស្រាយបញ្ហាអំពើហឹង្សារបស់ យុវជនជាមួយនឹងដំណោះស្រាយយ៉ាងទូលំ ទូលាយ ដែលរួមជាមួយនឹងយុទ្ធសាស្ត្រភស្តុតាង ជាមូលដ្ឋាន ព្រមទាំងជាមួយកំណើនគេហដ្ឋាន, កម្មវិធីទាំងឡាយដែលបានបង្កើតសំរាប់យុវជន, និងសហគមន៍។ នៅពេលដែលក្រុង Seattle មានបទពិសោធន៏នៃអត្រាឧក្រិដ្ឋកម្មតិចបំផុតជា ទូទៅច្រើនឆ្នាំ នោះចំនួនយុវជននៅតែបន្តជាបញ្ហាដល់សហគមន៍គួរឲ្យកត់សំគាល់។ សាលាក្រុងបានផ្សព្វផ្សាយបណ្ដើមគំនិតនិងដំណោះ ស្រាយក្នុងខែកក្កដាឆ្នាំ 2009 ដើម្បីផ្លាស់ប្ដូរ ដោយរំភើបពីរបៀបដែលសាលាក្រុងប្រឈម មុខជាមួយនឹងអំពើហឹង្សារបស់យុវជន។

## គោលបំណង

គោលបំណងនៃបណ្ដើមគំនិត គឺដើម្បីសំរេច ការបន្ថយចំនួន 50% ក្នុងការបញ្ជូនក្មេងទៅ តុលាការអនីតិជនសំរាប់អំពើហឹង្សា និងការ បន្ថយចំនួន 50% ក្នុងការបញ្ឈប់បណ្ដោះ អាសន្ន និងការបណ្ដេញចេញពីអនុវិទ្យាល័យ ដែលបានជ្រើសរើស ដោយយោងតាម ព្រិត្តិការណ៍នានាដែលទាក់ទងនឹងអំពើហឹង្សា។

## ជនណាមានលក្ខណសម្បត្តិទទួល?

បណ្ដើមគំនិតគឺផ្ដោតលើយុវជនចំនួនប្រហែល 800 នាក់ អាយុពី 12-17 ឆ្នាំដែលៈ

- ត្រូវបានគេផ្ដន្ទាទោសនៃការរំលោភលើអំពើហឹង្សានិងអ្វីៗដែលទាក់ទង;
- ត្រូវបានគេឃាត់ខ្លួនប៉ុន្តែមិនបានឃុំទុកទេ;
- ជាសិស្សនៅអនុវិទ្យាល័យដែលមានទម្លាប់ឈប់គ្មានច្បាប់ឬបញ្ឈប់បណ្ដោះអាសន្នជា ច្រើនដងដោយយោងលើចរិយាហឹង្សា; នឹង/ឬ
- ត្រូវបានទទួលរងគ្រោះដោយព្រឹត្តិការណ៍ ហឹង្សានៅក្នុងមូលដ្ឋានរបស់ពួកគេ។

ចំនួនទំហំនៃយុវជនដែលត្រូវបំរើគឺមានច្រើន ប្រភេទយ៉ាងទូលំទូលាយ និងសេចក្ដីត្រូវការ របស់ពួកគេមានភាពផ្សេងៗគ្នា។ យុវជនខ្លះ ដែលមានសេចក្ដីត្រូវការខ្ពស់នឹងទទួលសេវា ដែលមានមូលដ្ឋានលើការព្យាបាលនឹងល្អិត ល្អន់។ យុវជនផ្សេងៗទៀតនឹងទទួលបានសេវា ដែលនឹងជួយពួកគេឲ្យទទួលឱកាសដើម្បីធ្វើការ ជ្រើសរើសដោយវិជ្ជមាន។

បណ្ដើមគំនិតដោះស្រាយនៃក្រុង Seattle រួមបញ្ចូលនូវគោលការណ៍ នឹងចំណុចសំខាន់ៗ មកពីកម្មវិធីការពារអំពើហឹង្សាដោយជោគជ័យ ពីក្រុងដទៃផ្សេងៗ។ ដំណឹងពិតប្រាកដមួយ ដែលមានតាមរយៈភាពច្បាស់លាស់ខ្វះខ្វារ មកពីក្រុងដទៃផ្សេងៗគឺថារដ្ឋាភិបាលមិនគួរ សរសេរតាមគ្រប់ផែនការបណ្ដើមគំនិតដោះ ស្រាយយ៉ាងលំអិតនោះទេ។ ក្នុងការរក្សាទុក នូវដំបូន្មាននេះ សាលាក្រុងបានបង្កើតផែនការ មួយដែលបង្កើតភាពជាអ្នកដឹកនាំសហគមន៍។ នេះគឺបានធ្វើឡើងដោយការបង្កើតទីភ្នាក់ងារ ដែលមានមូលដ្ឋានលើសហគមន៍ ដែលជាដៃគូ នាំទៅរកបណ្ដាញមូលដ្ឋានបី ដែលបានបង្កើត ឡើងនៅក្រុង Seattle កណ្ដាល, អគ្នេយ៍, និងនីរតី។

## ទីភ្នាក់ងារទាំងឡាយណាជា បណ្ដាញនៅក្នុងមូលដ្ឋាន?

ទីភ្នាក់ងារនាំមុខដែលខំប្រឹងសម្របសម្រួល បណ្ដើមគំនិតគឺ: Therapeutic Health Services; Southwest Youth and Family Services;
និងការចូលរួមនៃទី ភ្នាក់ងារជាច្រើនដែលបានដឹកនាំដោយ Rainier Vista Boys and Girls Club ។

## តើមានសេវាអ្វីខ្លះ?

យុវជននឹងត្រូវបញ្ជូនឲ្យទទួលសេវានានា តាមរយៈសាលារៀន, ទីភ្នាក់ងារសហគមន៍, តុលាការនីតិជន, ប៉ូលិស, អ្នកធ្វើការផ្នែក មាគ៌ាទំនាក់ទំនង, នឹងមជ្ឈមណ្ឌលយុវជន ផ្នែកសួនច្បារនិងការកំសាន្តនៃក្រុង Seattle ។ កំរិតនៃសេវានានាដែលបាន សម្របសម្រួលត្រឹមកំរិតសហគមន៍មានរួមៈ

- មាគ៌ាទំនាក់ទំនង
- ការចាត់ចែងសំណុំរឿង
- ការហ្វឹកហ្វឺនការផ្លាស់ប្ដូរដែលបង្ខំ
- ការប្រៀនប្រដៅ
- ការងារធ្វើនិងការហ្វឹកហ្វឺនសំរាប់យុវជនស
- គំរោងមូលនិធិស៊ីនឹងមូលដ្ឋានសំរាប់ផ្ដល់ដល់យុវជនដែលមានលក្ខណសម្បត្តិ
- ការពន្យាពេលវេលានៃមជ្ឈមណ្ឌល សួនច្បារយុវជន ជាមួយនឹងកម្មវិធីដែល បង្កើតសំរាប់យុវជន

បន្ថែមលើនេះ "ឯកសណ្ឋានក្រុម" សាលា បញ្ជាក់ពីមន្ត្រីដែលបានចាត់តាំងសំរាប់ អនុវិទ្យាល័យបួន – Aki Kurose, Denny, Mercer, និង Washington Middle Schools and South Shore K-8 ។ សមាសភាគលក្ខណៈវិនិច្ឆ័យ ដទៃនៃបណ្ដើមគំនិតដោះស្រាយ គឺជាក្រុម មាគ៌ាទំនាក់ទំនងដែលបានបង្កើតឡើងពី បុគ្គលម្នាក់ៗដែលបានជឿជាក់ ដែលនឹង ជួបជាមួយយុវជន "នៅទីកន្លែងដែលពួក គេនៅ"។ មន្ត្រីសមត្ថកិច្ចសាលារៀន នឹង អ្នកធ្វើការទំនាក់ទំនងតាមផ្លូវនឹងស្ដាប់, ផ្ដល់ការណែនាំដល់យុវជន, ព័ត៌មាន, ជួយ ពួកគេដែលមានការពិបាកក្នុងដំណោះស្រាយនឹងលើកទឹកចិត្តឲ្យពួកគេធ្វើឲ្យមានសុខភាព ល្អ, ជំរើសជីវិជ្ជមាន។

មុននឹងចាប់ផ្ដើមបណ្ដើមគំនិតដោះស្រាយ ប៉ូលិសក្រុង Seattle ត្រូវបានបន្ថែមកង ល្បាត, បង្កើនចំនួនប៉ូលិសពីរដងដែលធ្វើការ ជាមួយក្រុមក្មេងពាលរបស់ពួកគេ។ ថ្ងៃថ្មីនៃ កងគំរូតផ្នែកក្មេងពាលគឺធ្វើការតាមសាលាជិត ខាង ដើម្បីបន្ថែមការឃាមល្បាតពីរយប់។

## មូលនិធី

សាលាក្រុងកំពុងធ្វើវិនិយោគចំនួន $8 លាន ដុល្លានៅពេលបណ្ដើមគំនិតក្នុងឆ្នាំ 2009 និង 2010, ដែលបង់ប្រាក់សំរាប់សេវាកម្មនិងកម្មវិធី នានាដែលមានរាយនៅក្នុងបណ្ណីនេះ។

## ព័ត៌មានបន្ថែម

**Mariko Lockhart**
នាយក, អង្គារបណ្ដើមគំនិតចារពារអំពើហឹង្សា នៃយុវជនក្រុង Seattle
mariko.lockhart@seattle.gov
206-233-7915

**Michael Garrett-Smalls**
អ្នកសម្របសម្រួលនៃបណ្ដាញ មជ្ឈមណ្ឌលមូលដ្ឋាន
michaelg@THS-WA.org
(206) 323-9014

**Nani Fatuesi**
អ្នកសម្របសម្រួលនៃបណ្ដាញ
មូលដ្ឋាននិរតី
nfatuesi@swyfs.org
206-937-7680 ext. 109

**Marty Jackson**
អ្នកសម្របសម្រួលនៃបណ្ដាញ
មូលដ្ឋានអគ្នេយ៍
mpatu@positiveplace.org
206-436-1898

**គេហទំព័រ:** www.safeyouthseattle.org